## អរិយធម៌បេនិន (Benin Civilization)

បេនិន(Benin) គឺជាឈ្មោះនៃអរិយធម៌ និងជាអាណាចក្រដ៏មានឥទ្ធិពលមួយនៅក្នុងតំបន់អាហ្វ្រិចខាងលិច ហើយសព្វថ្ងៃ គឺជាប្រទេសនីហ្សេរីយ៉ា( Nigeria)។ ប្រវត្តិសាស្ត្រនៃអរិយធម៌នេះ គឺកើតឡើងចេញពីក្រុមជនជាតិមួយក្រុមដែលហៅថា អ៊ីដូ(Edo) ដែលរស់នៅខាងត្បូងនៃប្រទេសនីហ្សេរីយ៉ា(រូបលេខ១)។

បេនិនបានក្លាយជាអាណាចក្រនៅស.វ.ទី១០នៃគ.ស. និងនៅស.វ.ទី១៥បានក្លាយជាអាណាចក្រដ៏មានអំណាចមួយនៅក្នុងតំបន់អាហ្វ្រិចខាងលិច ដោយ អូបា អ៊ីវៀ (Oba Ewuare)។[១] ចំពោះពាក្យ អូបា(Oba)ក្នុងប្រវត្តិសាស្ត្រនៃបេនិន មានន័យថាជា«ស្តេច»។ នៅក្នុងការគ្រប់គ្រងដោយ អូបា អ៊ីវៀ បានពង្រីក ទឹកដី និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងរាជធានីដែលសព្វថ្ងៃជាទីក្រុងបេនិន (Benin City) ឬហៅថា រដ្ឋអ៊ីដូ (Edo state) ដែលស្ថិតនៅខាងត្បូងនៃប្រទេសនីហ្សេរីយ៉ា (រូបលេខ២)

ទីក្រុងបេនិន ស្ថិតនៅខាងត្បូងនៃប្រទេសនីហ្សេរីយ៉ា និងមានចម្ងាយប្រមាណ ៣៦០ គីឡូពីរាជធានី អាប៊ូចា (Abuja)។ រចនាសម្ព័ន្ធដែលសំខាន់ជាងគេនៅក្នុងទីក្រុងបេនិន គឺជាកំពែងដីមានកម្ពស់ជាង១៨ម៉ែត្រ និងមានបណ្តោយប្រមាណ ១២០០គីឡូម៉ែត្រ[២] ដែលព័ទ្ធជុំវិញទីក្រុងនេះ ប៉ុន្តែកំពែងនេះត្រូវបានបំផ្លាញដោយ អង់គ្លេស អំឡុងពេលដែលដាក់អាណានិគមលើប្រទេសនីហ្សេរីយ៉ា ក្នុងស.វ.ទី១៩។ ចាប់ពីឆ្នាំ២០០២រហូតដល់២០០៦ គម្រោងមូលនិធិសំណង់ពិភពលោកបានមកជួសជុលសំណល់កំពែងដីនោះ។[៣]

វត្ថុសិល្បៈ នៃអរិយធម៌នេះជាច្រើនត្រូវបានទាហានអង់គ្លេសយកចេញពីប្រទេសនីហ្សេរីយ៉ា ទៅកាន់តំបន់អ៊ឺរ៉ុប។ នៅក្នុងឆ្នាំ ២០១២, លោក Robert Owen Lehman បានប្រគល់វត្ថុសិល្បៈជាច្រើននៃអរិយធម៌បេនិនដល់សាមន្ទីរសិល្បៈបូស្តុង (Museum of Fine Arts, Boston) ដែលមានចំនួនសរុប៣២វត្ថុ។ តាមរយៈវត្ថុសិល្បៈទាំងនោះបានបង្ហាញឱ្យ

[១] https://www.nationalgeographic.org/

[២] https://www.wmf.org/project/benin-city-earthworks

[៣] ibid

អត្ថបទដោយ៖ អេង តុលា

ឃើញអំពីទំនៀមទំលាប់វប្បធម៌ របស់មនុស្សក្នុងអរិយធម៌នេះ។[៤] គួរបញ្ជាក់ដែរថា Robert Owen Lehman គឺជាអ្នកប្រមូលរក្សាទុកវត្ថុសិល្បៈក្នុងតំបន់អាហ្វ្រិចដ៏ល្បីល្បាញម្នាក់ ចាប់ពីទ.វ.ទី ៨០មកម្ល៉េះ។ វត្ថុសិល្បៈទាំងនោះ គឺស្ថិតក្នុងសភាពល្អស្អាតដែលភាគច្រើន ធ្វើអំពីសំរិទ្ធ។ ប្រហែល៣៥០០វត្ថុសិល្បៈនៃអរិយធម៌បេនិនដែលផលិតអំពីស្ពាន់ និងអំពីភ្លុកសត្វ ដែលត្រូវបានរក្សាទុកនៅក្នុងបណ្ណាសារមន្ទីរបរទេសនៅអឺរ៉ុបនិង អាមេរិក ជាដើម ក្នុងនោះរួមមាននៅសារមន្ទីរចក្រភពអង់គ្លេស ([The British Museum](https://www.britishmuseum.org)) , ប៊ែកឡាំង, វេណា (Weltmuseum Vienna), ញូវយ៉ក (The Metropolitan Museum of Art) និងនៅឡាហ្គោសជាដើម[៤] (រូបលេខ៣-៥)។

មនុស្សក្នុងអរិយធម៌នេះមានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ប្លែក តែមានបច្ចេកទេសខ្ពស់ ដែលភាគច្រើនផលិតអំពីលោហៈធាតុ ដូចជាសំរិទ្ធ និងប្រាក់ជាដើម។ តាមរយៈវត្ថុសិល្បៈទាំងនោះ អាចបង្ហាញថា អរិយធម៌បេនិន គឺពូកែខាងលោហៈកម្ម ដែលខ្ញុំធ្លាប់បានបង្ហាញកាលពីអត្ថបទមុនៗរួមមកហើយ ដោយអរិយធម៌នៅក្នុងទ្វីបអាហ្វ្រិចភាគច្រើនគឺជំនាញខាងផ្នែកផលិតលោហៈធាតុដូចជា បច្ចេកទេសចម្រាញ់ដែកពីរ៉ែ និងបច្ចេកទេសស្មិតលោហធាតុឱ្យទៅជាវត្ថុសិល្បៈផ្សេងៗ ដែលបញ្ជាដោយស្តេច ឬមន្ត្រីដែលទម្រង់ទាំងនោះ គឺស្របទៅនឹងសង្គមរបស់ពួកគេ។ វត្ថុសិល្បៈបុរាណក្នុងអរិយធម៌បេនិនភាគច្រើនគឺធ្វើឡើង ដើម្បីឧទ្ទេស និងគោរពដល់អូបា (ស្តេច) នៃអាណាចក្របេនិន (រូបលេខ ៦-៧)។

អាណាចក្របេនិនត្រូវដួលរលំ និងបញ្ចប់នៅស.វ.ទី១៩ ដោយសារការឈ្លានពាន និងដាក់អាណានិគមពីសំណាក់ចក្រភពអង់គ្លេស។

សរុបមក អរិយធម៌ និងអាណាចក្រមានអាយុកាល៩ស.វ និងជាអរិយធម៌ដែលមានអំណាចក្នុងចំណោមអរិយធម៌ក្នុងតំបន់អាហ្វ្រិចខាងលិច។ ទិន្នន័យទាំងអស់នេះ គឺបង្ហាញតាមរយៈការសិក្សាលើវត្ថុសិល្បៈដែលសេសសល់ និងវត្ថុសិល្បៈរក្សាទុកនៅបណ្ណាសារមន្ទីរបរទេស ដែលបានបង្ហាញពីខាងលើ៕

---

[៤] Art of the Benin Kingdom | Museum of Fine Arts, Boston (mfa.org)

[៤] ibid

អត្ថបទដោយ៖ អេង តុលា






រូបលេខ១-២៖ ផែនទីនៃអាណាចក្របេនិន និងរូបកំពែងនៃទីក្រុងបេនិន (ប្រភព៖ https://www.metmuseum.org)



រូបលេខ៣-៥៖ វត្ថុសិល្បៈក្នុងអរិយធម៌បេនិន ត្រូវបានដាក់តាំងបង្ហាញនៅសារមន្ទីរ ប៊ូស្តុង (ប្រភព៖ https://www.mfa.org/news/benin-kingdom)





អត្ថបទដោយ៖ អេង តុលា





រូបលេខ៦ & ៧៖ វត្ថុសិល្បៈក្នុងអរិយធម៌បេនិនអំពីប្រាក់

ប្រភព៖ https://www.metmuseum.org

ឯកសារយោង


https://www.wmf.org/project/benin-city-earthworks

Art of the Benin Kingdom | Museum of Fine Arts, Boston (mfa.org)

https://www.nationalgeographic.org


អត្ថបទដោយ៖ អេង តុលា